ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូង ខេត្តកំពង់ឆ្នាំង**
សំណុំរឿងព្រហ្មទណ្ឌលេខ:២១១
ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១២
សាលក្រមលេខ:០៥ (ក)
ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២១

## តាមនាមប្រជារាស្ត្រខ្មែរ

តុលាការសាលាដំបូងខេត្តកំពង់ឆ្នាំង បានបើកសវនាការជាសាធារណៈនៅនាទីសាលាដំបូងខេត្តកំពង់ឆ្នាំង ដោយមានសមាសភាពជំនុំជំរះដូចតទៅ:

- **ឯកឧត្តម** [redacted] ចៅក្រមជំនុំជំរះ
- លោក ចៅក្រមប្រឹក្សា
- លោក ចៅក្រមប្រឹក្សា
- លោក តំណាងអយ្យការ
- លោក ក្រឡាបញ្ជីសវនាការ

-ជនជាប់ចោទមានមេធាវីការពារឈ្មោះ [redacted] និង ឈ្មោះ [redacted] ។

## ដើម្បីជំនុំជំរះ

សំណុំរឿងព្រហ្មទណ្ឌលេខ: ២១១ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១២ មាន:

-ជនជាប់ចោទឈ្មោះ [redacted] **អៀង** ភេទស្រី កើតថ្ងៃទី២០ ខែមករា ឆ្នាំ១៩៥៨ ជាតិខ្មែរ របររកស៊ីលក់ដូរ និងធ្វើចំការ ទីកន្លែងកំណើត និង ទីលំនៅភូមិ[redacted] ខេត្តកំពង់ឆ្នាំង ឪពុកឈ្មោះ [redacted] ប៉ក់(ស្លាប់) ម្តាយឈ្មោះ[redacted]ងួន (ស្លាប់) ប្តីឈ្មោះ [redacted] ជិបហាក់ (រស់) មានកូន០៥នាក់ ទោសពីមុនគ្មាន ។

ជាប់ចោទពីបទ: កាប់រានឈូសឆាយហ៊ុំព័ទ្ធកាន់កាប់ដីព្រៃ ប្រព្រឹត្តនៅភូមិទំនប់ ឃុំត្រងិល ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១២ ដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៩៧ កថាខណ្ឌ១ ចំណុច៦នៃច្បាប់ស្តីពីព្រៃឈើ ។

-ដើមបណ្តឹងរដ្ឋប្បវេណី តំណាងអយ្យការ ។

- **បានឃើញ:** កំណត់ហេតុបទល្មើសលេខ:០០៧ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១២ ។
- **បានឃើញ:** ដីកាសន្និដ្ឋានស្ថាពរចោទប្រកាន់លេខ:២៩៥២ ដ.ស.ព ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៣ ។
- **បានឃើញ** : ដីកាដំណោះស្រាយបញ្ជូនរឿងមកជំនុំជំរះលេខ: ៣៦២ /១៣ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ ២០១៣ ។

## ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ:

កាលពីថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១២ ឈ្មោះ [redacted] អៀង បានធ្វើការរុករានទន្ទ្រាន ហ៊ុំព័ទ្ធយកដីព្រៃ គម្របព្រៃឈើឆ្នាំ២០០២ ធ្វើជាកម្មសិទ្ធិអស់ទំហំ១៣ ហិចតា ៧២៨ ដោយគ្មានលិខិតអនុញ្ញាតពីរដ្ឋបាលព្រៃឈើ ។

-អង្គហេតុនៅមន្ត្រីរដ្ឋបាលព្រៃឈើបានដាក់ការសង្ស័យទៅលើជនសង្ស័យឈ្មោះ [redacted] អៀង ក្នុងបទ:កាប់រានព្រៃឈូសឆាយដីព្រៃហ៊ុំព័ទ្ធដោយគ្មានលិខិតអនុញ្ញាត ។

-អង្គហេតុពេលមកដល់តំណាងអយ្យការបានសន្និដ្ឋានចោទប្រកាន់លើឈ្មោះ [redacted] អៀង ពីបទ:កាប់រានឈូសឆាយដីព្រៃហ៊ុំព័ទ្ធកាន់កាប់ដីព្រៃ ។

Scanned with CamScanner

-អង្គហេតុនៅពេលដល់ចៅក្រមស៊ើបសួរបានបញ្ជូនជនជាប់ចោទឈ្មោះ [redacted] អៀង មកជំនុំជំរះ ពីបទៈ កាប់រានហ៊ុំព័ទ្ធកាន់កាប់ដីព្រៃ ។

## នារពលសខនាការ

-ជនជាប់ចោទឈ្មោះ [redacted] អៀង បានឆ្លើយថា ខ្លួនមិនចាំថ្ងៃ ខែ ឆ្នាំ កើតហេតុទេ ដីដែលរដ្ឋបាលព្រៃឈើប្តឹង ខ្លួនបានទិញពីគេចំនួនបួនហិចតា ក្នុងតម្លៃមួយហិចតាចំនួនមួយលានរៀល មានលិខិតទិញលក់ត្រឹមត្រូវ ។ ក្រោយពីទិញឱ្យគេកាប់ព្រៃមានតែគល់ឈើ និង ដើមឈើតូចៗ ខ្លួនកាប់កូនឈើដោយខ្លួនឯងខ្លះ និង ជួលអាអ៊ិចរបស់ក្មួយឱ្យជួយដកគល់ឈើ ខាងរដ្ឋបាលព្រៃឈើថាខ្លួន ឈូសឆាយដីព្រៃ ។ ក្រោយមកទៀតនៅឆ្នាំ២០១៤ និង ឆ្នាំ២០១៥ ខ្លួនទិញដីព្រៃបន្ថែម ពុំមានអាជ្ញាធរភូមិឃុំស៊ីញ៉េឱ្យទេ ឈូសឆាយបន្ថែមទៀត សរុបទាំងមុន និង ទិញបន្ថែមចំនួន១៣ហិចតាជាង មូលហេតុដែលខ្លួនពុំបានឱ្យមេភូមិ-ឃុំ ស៊ីញ៉េដោយសារតែខ្លួនទិញម្តងបានបន្តិចៗ មានក្បាល១៥ម៉ែត្រ ក្បាល២០ម៉ែត្រ ។ ខ្លួនដឹងថាដីតម្រេបព្រៃឈើឆ្នាំ២០១២ ត្រូវបានគេលើកលែងឱ្យហើយ ទើបទិញបន្ថែម បច្ចុប្បន្នមានដាំដំណាំអស់ហើយ ពុំមានអ្នកណាហាមឃាត់ទៀតទេ ។

-មន្ត្រីរដ្ឋបាលព្រៃឈើឈ្មោះ [redacted] ដារ៉ា បានឆ្លើយថា ក្នុងខែមេសា ឆ្នាំ២០១២ មានលិខិតរបស់អភិបាលស្រុកឈ្មោះ [redacted] អៀនលី ស្នើមករដ្ឋបាលព្រៃឈើ ដោយសុំឱ្យមេភូមិ-មេឃុំមានវិធានការទប់ស្កាត់ ការកាប់រានឈូសឆាយដីព្រៃរបស់រដ្ឋ ទើបមានការចុះទៅដល់កន្លែងកើតហេតុ ឃើញឈ្មោះ [redacted] អៀង ធ្វើការរុករាន គាស់គល់ថ្មីៗ ទៅដល់ឃើញឈ្មោះនេះកំពុងតែនៅកន្លែងកើតហេតុ មិនឃើញមានឧបករណ៍អ្វីទេ ពេលនោះជំនាញបានធ្វើការវាស់វែងដោយប្រើនិយាមការខ្សែបិទជិតនេះ បើតាមឯកសាររបស់មន្ត្រីជំនាញមុន ។ ក្នុងការពិនិត្យពុំឃើញមានលិខិតណាប្រគល់ដីនេះឱ្យទៅសាមីខ្លួនឡើយ បើអាជ្ញាធរខេត្តថាដីអាស្រ័យផល ខាងជំនាញមិនដែលកាត់ឱ្យនោះទេ នៅពេលធ្វើកំណត់ហេតុនោះឈ្មោះ [redacted] អៀង បានប្រកែកមិនព្រមផ្តិតមេដៃឡើយ ក្នុងនាមរដ្ឋបាលព្រៃឈើ សុំឱ្យតុលាការសម្រេចតាមការចោទប្រកាន់ តាមសាលាកប័ត្រទោសទណ្ឌ ។

-តាមអំណានសាក្សីឈ្មោះ [redacted] ហេន បានឆ្លើយថា ខ្លួនទទួលតំណែងមេភូមិទំនប់ នៅថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១២ ក្រោយពេល មេភូមិចាស់ទទួលមរណៈភាព ឈ្មោះ [redacted] អៀង និងប្តីឈ្មោះ [redacted] ជីបហាក់ ទិញដីចំការពីឈ្មោះ [redacted] ភាព និងប្រពន្ធឈ្មោះ [redacted] សេត ខ្លួនមិនដឹងទេ ខ្លួនមានដីចំការមួយកន្លែង ដែលមានព្រំជាប់ឈ្មោះ [redacted] អៀង ជាប់ព្រំខាងត្បូង ។ ពេលឈ្មោះ [redacted] ភាព គ្រប់គ្រងដីនេះ បានធ្វើស្រែមួយចំនួនហើយ នៅព្រៃរបោះៗមួយចំនួន ក្រោយឈ្មោះ [redacted] អៀង ទិញបានកាប់ឆ្ការឈូសឆាយដាំដើមស្វាយ ចេក ដូង នៅពេលឈ្មោះ [redacted] អៀង ធ្វើការឈូសឆាយ ខាងរដ្ឋបាលព្រៃឈើចុះហាមឃាត់ដែរ ឈ្មោះ [redacted] អៀង ក៏បញ្ឈប់សកម្មភាព ដីសហគមន៍ព្រៃឈើនៅផ្នែកខាងជើង ផ្លូវលំពេជ្រឡា និង ដីរបស់ឈ្មោះ [redacted] អៀង នៅខាងត្បូងផ្លូវលំពេជ្រឡា មិនចូលដីសហគមន៍ទេ ដីនៅចំណុចបុសមឿងនេះ ប្រជាពលរដ្ឋចូលទៅកាប់រានយករៀងៗខ្លួន មិនមានអាជ្ញាធរណាបែងចែកឱ្យទេ ។

-តាមអំណានសាក្សីឈ្មោះ [redacted] សេត បានឆ្លើយថា នៅឆ្នាំ១៩៨៥ ខ្លួននិងប្តីឈ្មោះ [redacted] ភាព បានចូលទៅកាប់ឆ្ការរានយកដីនៅ ចំណុចបុសមឿងស្ថិតនៅក្នុងភូមិទំនប់ ឃុំត្រងិល ទំហំ០១ហិចតា មិនចាំបណ្តោយទទឹងទេ មិនមានអាជ្ញាធរណាបែងចែកឱ្យឡើយ ។ ខ្លួនបានដាំស្រូវសណ្តែករហូតមកដល់ចុងឆ្នាំ២០១២ កូនមានជម្ងឺ គ្មានប្រាក់ព្យាបាលក៏លក់ដីនេះទៅឱ្យឈ្មោះ ហុង ជីបហាក់ និង ប្រពន្ធឈ្មោះ យ៉ែម អៀង បានមួយលានរៀលជាដីចំការ និងដាំស្រូវ វាលអស់ហើយ មិនមានព្រៃទេ ចំពោះកិច្ចសន្យាទិញលក់ដីចុះថ្ងៃទី១១ ខែមិនា ឆ្នាំ២០១២ នោះ គឺខ្លួនលក់បីនាក់បងប្អូន ឈ្មោះ [redacted] នី និង ឈ្មោះ [redacted] តា នៅភូមិចំបក់ខ្ពស់ ឃុំស្វាយរំពារ ដែលមានដីនៅជាប់ព្នានឹងខ្លួន ។ ពេលខ្លួននៅគ្រប់គ្រងដីនោះមិនមានរដ្ឋអំណាចមកហាមឃាត់ទេ ដីរបស់ខ្លួននៅខាងត្បូងផ្លូវលំពេជ្រម្បា ។

-តាមអំណានសាក្សីឈ្មោះ [redacted] គីមធី បានឆ្លើយថា ខ្លួនចុះហត្ថលេខាទទួលស្គាល់លើកិច្ចសន្យាទិញលក់ដីធ្លីចុះថ្ងៃទី១១ ខែមិនា ឆ្នាំ២០១២ រវាងឈ្មោះ [redacted] ភាព និង ឈ្មោះ [redacted] អៀង និង លិខិតស្នើសុំបញ្ជាក់អចលនៈទ្រព្យរបស់ឈ្មោះ [redacted] ជីបហាក់ ចុះថ្ងៃទី១១ ខែមិនា ឆ្នាំ២០១២ ការចុះហត្ថលេខារបស់ខ្លួនសំអាងលើមេភូមិទំនប់ឈ្មោះ ផូ បាន បានអះអាងថាដីនេះ ជារបស់ឈ្មោះ [redacted] ភាព និងប្រពន្ធឈ្មោះ [redacted] សេត មិនមានពាក់ព័ន្ធជាមួយដីសហគមន៍ទេ ខ្លួនមិនបានចុះទៅពិនិត្យស្ថានភាពដីទេ ដីនៅបុសមឿង សុទ្ធតែធ្វើតាំងពីឆ្នាំ១៩៨០-១៩៨១ មុនកើតមានផ្លូវពេជ្រឡាម្ល៉េះ មិនចូលដីសហគមន៍ តែចូលដីគម្របព្រៃឆ្នាំ២០០២ ។

-តាមអំណានសាក្សីឈ្មោះ [redacted] ជីបហាក់ បានឆ្លើយថា ខ្លួន និង ប្រពន្ធឈ្មោះ [redacted] អៀង បានទិញដីទំហំ២៨២,៥ ម៉ែត្រ គុណនឹង១៤០ម៉ែត្រ ពីឈ្មោះ [redacted] ភាព និង ប្រពន្ធឈ្មោះ [redacted] សេត ពិតប្រាកដមែន ក្នុងតម្លៃ ៣,០០០,០០០ រៀល ដីដែលខ្លួនបានទិញនោះ ស្ថិតនៅក្នុងភូមិទំនប់ ឃុំត្រងិល ដែលរដ្ឋបាលព្រៃឈើហាមឃាត់ធ្វើការឈូសឆាយនោះ មុនពេលទិញដីនោះ ខ្លួនបានសួរនាំ មេភូមិទំនប់ និង មេឃុំត្រងិល ថាដីនោះមិនមានពាក់ព័ន្ធជាមួយសហគន៍ព្រៃឈើទេ ទើបខ្លួនទិញ ក្រោយពេលទិញហើយ ខ្លួនបានឈូសឆាយធ្វើរបងព័ទ្ធជុំវិញ ដាំដំណាំ និងធ្វើស្រែ ដោយសំអាងលើកិច្ចសន្យាចុះថ្ងៃទី១១ ខែមិនា ឆ្នាំ ២០១២ និង លិខិតស្នើសុំបញ្ជាក់ចុះថ្ងៃទី១១ ខែមិនា ឆ្នាំ២០១២ លុះពេលខ្លួនឈូសឆាយធ្វើរបងដាំដំណាំរួចហើយ ទើបខាងរដ្ឋបាលព្រៃឈើចុះទៅហាមឃាត់ ខ្លួនក៏ឈប់ប្រមូលទិញដីនៅទីនោះទៀត ខ្លួនមិនចាំថា ដីប្រពន្ធខ្លួនទិញ មានទំហំប៉ុន្មានទេ ខ្លួនមិនដាក់ពាក្យសុំកាន់កាប់ដីធ្លីឡើយ ។

-តាមអំណានចម្លើយមន្ត្រីរដ្ឋបាលព្រៃឈើឈ្មោះ [redacted] មករា បានឆ្លើយថា កាលថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១២ សង្កាត់រដ្ឋបាលព្រៃឈើ រលាប្អៀរ កំពង់លែង បានទទួលរបាយការណ៍ពីអភិបាលស្រុកកំពង់លែង នៅថ្ងៃទី០៩ ខែឧសភា ឆ្នាំ ២០១២ សង្កាត់រដ្ឋបាល ព្រៃឈើរលាប្អៀរ កំពង់លែង សហការណ៍ជាមួយមេឃុំស្វាយរំពារ ឃុំត្រងិល មេប៉ុស្តិ៍នគរបាលរដ្ឋបាលត្រងិល មេភូមិត្រងិល មេភូមិចំបក់ខ្ពស់ សហគមន៍ព្រៃឈើកងរី ពោធិ៍បាំងក្រសាំងតែងខ្លួន និង ក្រុមប្រឹក្សាស្រុក បានចុះទៅដល់កន្លែងកើតហេតុ ឃើញមានការកាប់ឆ្ការ និង ឈូសឆាយថ្មីៗ លើផ្ទៃដីទំហំ១៣ហិចតា៧២៨ម៉ែត្រការ៉េ នៅចំណុចគោកមឿង ខ្នាតូច ស្ថិតនៅភូមិទំនប់ ឃុំត្រងិល ពេលនោះបានជួបកម្មករដែលកាប់ព្រៃឱ្យឈ្មោះ [redacted] អៀង គាត់ប្រាប់ថាជាដីរបស់ឈ្មោះ [redacted] អៀង ក្រោយពីការសាកសួរ គាត់ថាទិញពីគេ ហើយសមត្ថកិច្ចក៏បានហាមឃាត់មិនឱ្យធ្វើសកម្មភាពបន្តចំពោះដីទំហំ១៣ហិចតា ៧២៨ម៉ែត្រការ៉េ មិនមែន ឈ្មោះ [redacted] អៀង ឈូសឆាយហ៊ុំព័ទ្ធយកទាំងអស់នោះទេ គឺមានអ្នកផ្សេងទៀតដែរ ។

-តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថា ឆ្លងកាត់ការស្ដាប់ចម្លើយរបស់ជនជាប់ចោទ សាក្សីមេភូមិ មេឃុំ និង មន្ត្រីជំនាញរដ្ឋបាលព្រៃឈើ ឃើញថាកាលពីថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១២ នៅចំនុចភូមិទំនប់ ឃុំត្រងិល ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង មានឈ្មោះ [redacted] អៀង បានធ្វើការកាប់ឆ្ការ ហ៊ុំព័ទ្ធកាន់កាប់ដីព្រៃ គម្របព្រៃឈើឆ្នាំ២០០២ អស់ទំហំ ១៣ហិចតា ៧២៨ម៉ែត្រការ៉េ នៅពេលមន្ត្រីជំនាញចុះទៅដល់កន្លែងកើតហេតុផ្ទាល់ បានសាកសួរទៅលើកម្មករដែលកាប់នោះ ថាជារបស់ឈ្មោះ [redacted] អៀង ពិតប្រាកដមែន ដូចនេះក្នុងនាមតំណាងអយ្យការ នៅតែសុំតម្កល់សេចក្ដីសន្និដ្ឋានចោទប្រកាន់ទុកជាបានការដដែល និង ប្ដឹងសុំឱ្យតុលាការសម្រេចផ្ដន្ទាទោសជនជាប់ចោទទៅតាមច្បាប់ ។

-មេធាវីការពារជនជាប់ចោទបានធ្វើសេចក្ដីសន្និដ្ឋានថា ជនជាប់ចោទពុំមានចេតនាប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់នោះទេ ដោយមានមូលហេតុពីរយ៉ាងគឺ

យោងតាមមាត្រា៤នៃក្រមព្រហ្មទណ្ឌបានចែងថា ពុំមានបទល្មើសទេ ប្រសិនបើគ្មានចេតនាប្រព្រឹត្ត តាមកំណត់ហេតុសួរចម្លើយជនជាប់ចោទ និង សាក្សី បានបញ្ជាក់ថា ជនជាប់ចោទ ពុំមានចេតនាកាប់រានឈូសឆាយហ៊ុំព័ទ្ធដីព្រៃដូចការចោទ

ប្រកាន់នោះឡើយ ។ មូលហេតុដែលជនជាប់ចោទបានឈូសឆាយដី គឺមានបំណងសម្រាប់ដាំដំណាំ តែប៉ុណ្ណោះ ដោយគិតថាដីនោះ ជនជាប់ចោទបានទិញពីម្ចាស់មុនរួចហើយកាលពីថ្ងៃទី១១ ខែមីនា ឆ្នាំ២០១២ ហើយមានការបញ្ជាក់ពីមេភូមិ-មេឃុំថាដីនោះពុំមានជាប់ពាក់ព័ន្ធអ្វីដែរ មានការស៊ីសង្វាក់ទៅនឹងសាក្សីឈ្មោះ [redacted] ជិបហាក់ ដូចជនជាប់ចោទ .សាក្សីឈ្មោះ [redacted] គឹមធី ថាដីនៅតំបន់នោះប្រជាជនចូលធ្វើតាំងពីឆ្នាំ១៩៨០-១៩៨១មកម្លេះ .សាក្សីឈ្មោះ[redacted]ហេន ថាដីនោះម្ចាស់ដីឈ្មោះ[redacted]ភាព បានធ្វើស្រែមួយចំនួនហើយ មុននឹងលក់ដីនោះឱ្យជនជាប់ចោទ .សាក្សីឈ្មោះ [redacted] សេត ថាដីដែលខ្លួនលក់នោះ បានកាន់កាប់នឹងឈូសឆាយធ្វើស្រែចំការតាំងពីឆ្នាំ១៩៨៥ ពុំមានព្រៃទេ ។ ដូចនេះការឈូសឆាយដី ពុំមែនធ្វើឡើងដោយចេតនាកាប់បំផ្លាញទន្ទ្រានយកដីព្រៃនោះទេ ពីព្រោះជនជាប់ចោទពុំដឹងថាដីនោះ ស្ថិតនៅក្នុងតម្រុបព្រៃឈើឡើយ ការឈូសឆាយដីធ្វើឡើង ដោយគិតថាខ្លួនជាម្ចាស់ស្របច្បាប់លើដីនោះ ហើយគ្រាន់តែជាការធ្វើដីឱ្យស្អាតដើម្បីបង្ករបង្កើនផលប៉ុណ្ណោះ ។

ពុំមានភស្តុតាងច្បាស់ណាមួយបញ្ជាក់ថាជនជាប់ចោទបានកាប់រានឈូសឆាយហ៊ុំព័ទ្ធដីព្រៃនោះទេ ដោយហេតុថាតាមកំណត់ហេតុសួរចម្លើយជនជាប់ចោទ និង សាក្សី បានបញ្ជាក់ថាគ្មានភស្តុតាងជាក់ច្បាស់ថាជនជាប់ចោទកាប់រានឈូសឆាយហ៊ុំព័ទ្ធដីព្រៃនោះទេ ដោយមូលហេតុថា:

១-ដីដែលជនជាប់ចោទបានទិញដី មានព្រំប្រទល់ជុំវិញជាប់នឹងម្ចាស់ដីដទៃទៀត ដូចនេះប្រជាជនពិតជាប្រើប្រាស់សម្រាប់ បង្ករបង្កើនផលជាក់ជាមិនខាន ។

២-មេឃុំបញ្ជាក់ថាដីតំបន់នោះប្រជាជនចូលធ្វើតាំងពីឆ្នាំ១៩៨០-១៩៨១ មកម្លេះ ។

៣-មេភូមិទំនប់បានបញ្ជាក់ថាម្ចាស់ដីដើមបានធ្វើស្រែលើដីនោះ មុនពេលដែលជនជាប់ចោទបានទិញដីនោះ ។

៤-សាក្សីឈ្មោះ[redacted]សេត ថាដីលក់នោះគ្មានព្រៃនោះទេ ពីព្រោះខ្លួនធ្វើស្រែចំការតាំងពីឆ្នាំ១៩៨៥មកម្លេះ ។

៥-សាក្សីឈ្មោះ[redacted] មករា ជាមន្ត្រីរដ្ឋបាលព្រៃឈើ បានបញ្ជាក់ថា ដីដែលឈូសឆាយចំនួន១៣ហិចតា មិនមែនជនជាប់ចោទឈូសឆាយហ៊ុំព័ទ្ធតែម្នាក់ឯងនោះទេ គឺមានអ្នកផ្សេងទៀត ។

៦-រូបថតបង្ហាញពីការគាស់ រំលើងដើមឈើ មិនបានបញ្ជាក់ថា វាស្ថិតនៅក្នុងបរិវេណដីរបស់ជាប់ចោទឡើយ ហើយក៏មិនបញ្ជាក់ថាជនជាប់គាស់កកាយនោះដែរ ព្រោះវាអាចជាទង្វើរបស់អ្នកដទៃ ។

ដោយហេតុថាពុំមានភស្តុតាងដែលមានស្ថានទម្ងន់គ្រប់គ្រាន់ណាមួយបង្ហាញថា ជនជាប់ចោទ ពិតជាបានឈូសឆាយដីព្រៃនោះទេ ដូចនេះយោងតាមមាត្រា៣៥១នៃក្រមនីតិវិធីព្រហ្មទណ្ឌ រាល់វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជាប់ចោទ ។

សំណូមពរសុំឱ្យក្រុមប្រឹក្សាសម្រេចលើកលែងជនជាប់ចោទឱ្យរួចផុតពីបទចោទប្រកាន់ ស្តីពីបទ កាប់រានឈូសឆាយហ៊ុំព័ទ្ធដីព្រៃដោយគ្មានលិខិតអនុញ្ញាតិ តាមបញ្ញត្តិមាត្រា៩៧ កថាខណ្ឌ១ចំណុច៦នៃច្បាប់ស្តីពីព្រៃឈើ ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ ។

-ក្រោយពីបានស្តាប់ចម្លើយសាក្សី ។

-ក្រោយពីបានស្តាប់ចម្លើយមន្ត្រីរដ្ឋបាលព្រៃឈើ ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ ។

-ក្រោយពីបានស្តាប់សេចក៏សន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ ។

-ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ ។

Scanned with CamScanner

## សាលាដំបូងខេត្តកំពង់ឆ្នាំង

## យល់ឃើញថា

-តាមកំណត់ហេតុបទល្មើស ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១២ របស់មន្ត្រីរដ្ឋបាលព្រៃឈើ បានបង្ហាញថាកាលពីថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១២ មានឈ្មោះ យ៉ែម អៀង បានកាប់រាន កាន់កាប់ឈូសឆាយដីព្រៃជាគម្របព្រៃឈើឆ្នាំ២០០២ អស់ទំហំ១៣ ហិចតា ៧២៨ម៉ែត្រការ៉េ នៅចំនុចភូមិទំនប់ ឃុំត្រងិល ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង ដោយហេតុថាជនជាប់ចោទបានឆ្លើយសារភាពរួចហើយ ។

-អំពើប្រព្រឹត្តរបស់ជនជាប់ចោទ បានបណ្តាលអន្តរាយដល់ធនធានព្រៃឈើ ដែលច្បាប់បានការពារមិនឱ្យមានការបំផ្លិចបំផ្លាញ ដែលនាំឱ្យប៉ះពាល់ដល់បរិស្ថាន ។

-អំពើប្រព្រឹត្តរបស់ជនជាប់ចោទមានចេតនាចង់ឱ្យព្រៃឈើវិនាសអន្តរាយ និង យកដីមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន ដែលសកម្មភាពចូលកាន់កាប់ជាអំពើខុសច្បាប់ ដែលច្បាប់កំណត់ថាជាបទល្មើសតម្រូវឱ្យផ្តន្ទាទោស ។

- សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការដែលបានលើកឡើង ដោយផ្អែលើចម្លើយជនជាប់ចោទ សាក្សីមេភូមិ មេឃុំ និង មន្ត្រីជំនាញរដ្ឋបាលព្រៃឈើ បង្ហាញថាជនជាប់ចោទឈ្មោះ [redacted] អៀង បានធ្វើការកាប់ឆ្ការ ហ៊ុំព័ទ្ធកាន់កាប់ដីព្រៃ គម្របព្រៃឈើឆ្នាំ២០០២ អស់ទំហំ១៣ហិចតា ៧២៨ម៉ែត្រការ៉េ ។ ដោយតំណាងអយ្យការនៅតែសុំតម្កល់សេចក្តីសន្និដ្ឋានចោទប្រកាន់ទុកជាបានការដដែល និង ប្តឹងសុំឱ្យតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទទៅតាមច្បាប់ គប្បីតុលាការពិចារណា ។

-សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទដែលបានលើកឡើងដោយផ្អែកលើថារឿងនេះពុំមានចេតនាប្រព្រឹត្តបទល្មើស និង ពុំមានភស្តុតាងដាក់បន្ទុក ឃើញថាតុលាការពុំអាចពិចារណាបានឡើយ ដោយហេតុថាជនជាប់ចោទបានឆ្លើយសារភាពរួចហើយថា ខ្លួនកាប់កូនឈើដោយខ្លួនឯងខ្លះ និង ជួលអាអ៊ិចរបស់ក្មួយឱ្យជួយដកគល់ឈើទាំងអស់នោះ និង មានការទិញពង្រីកបន្ថែមទៀត ។

- ជនជាប់ចោទ ទើបប្រព្រឹត្តបទល្មើសជាលើកដំបូង និង មានជំងឺរ៉ាំរ៉ៃប្រចាំកាយ គប្បីតុលាការផ្តល់នូវស្ថានសម្រាលដល់ជននេះ តាមមាត្រា១០៧នៃក្រមព្រហ្មទណ្ឌ ដើម្បីឱ្យជននេះមានឱកាសធ្វើការកែប្រែខ្លួន ឱ្យទៅជាពលរដ្ឋល្អក្នុងសង្គម ។

## <u>ហេតុដូច្នេះសាលាដំបូងខេត្តកំពង់ឆ្នាំង</u>

## វិនិច្ឆ័យសេចក្តី

១- ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] អៀង ភេទស្រី កើតថ្ងៃទី២០ ខែមករា ឆ្នាំ១៩៥៨ ជាតិខ្មែរ (សាវតាជាតិមានក្នុងសំណុំរឿងស្រាប់) ដាក់ពន្ធនាគារចំនួន០៥(ប្រាំ)ឆ្នាំ តែទោសនេះត្រូវព្យួរធម្មតា ពីបទៈ កាប់រានឈូសឆាយហ៊ុំព័ទ្ធកាន់កាប់ដីព្រៃ ប្រព្រឹត្តនៅភូមិទំនប់ ឃុំត្រងិល ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១២ តាមមាត្រា៩៧ កថាខណ្ឌ១ ចំណុច៦ នៃច្បាប់ស្តីពីព្រៃឈើ និង មាត្រា១០៧នៃក្រមព្រហ្មទណ្ឌ ។

២-សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] អៀង និង ប្រកាសជាសាធារណៈ នៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២១ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] អៀង ទុកសិទ្ធិឱ្យប្តឹងទាស់ និង ប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|---|
| [redacted] | [redacted] | [redacted] | [redacted] |